# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

## ការិយាល័យនាយិការផ្នែកសិក្សាធិការ

**440 N. Broad Street, Suite 210**
**Philadelphia, PA 19130**

**Penny Nixon** ទូរស័ព្ទ៖ ២១៥-៤០០-៤២០០
នាយិការផ្នែកសិក្សាធិការ ទូរសារ៖ ២១៥-៤០០-៤២០១

ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២

ជូនចំពោះ មាតាបិតា និងអាណាព្យាបាល៖

ឆ្នាំសិក្សានេះ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា យកការប្រឡង ឃីស្តូន (Keystone) ដែលរដ្ឋបានអនុញ្ញាតឲ្យ មកជំនួសការប្រឡង PSSA វិញ។ ការប្រឡងទាំងនេះស្របតាមខ្នាតគំរូសំខាន់ទូទៅថ្មីៗរបស់រដ្ឋ ហើយអាចវាយតម្លៃការស្ទាត់ជំនាញផ្នែក ពិជគណិតកម្រិត១ អក្សរសិល្ប៍ និង ជីវវិទ្យា (Algebra 1, Literature, and Biology) របស់សិស្សានុសិស្សថ្នាក់ទី១១របស់យើង។ ការប្រឡងទាំងនេះនឹងប្រព្រឹត្តទៅនៅ ខែមករា ឆ្នាំ២០១៣។ ជាបន្ថែមទៀត សិស្សានុសិស្សណាដែលរៀនចប់ ពិជគណិតកម្រិត១ អង់គ្លេសកម្រិត II និង/ឬ ជីវវិទ្យា (Algebra 1, English II, and/or Biology) ក៏ត្រូវចូលរួមក្នុងការប្រឡង Keystone ក្នុងពេលជាមួយគ្នានឹងសិស្សានុសិស្សថ្នាក់ទី១១ ដែរ។ បើសិនជាពួកគេប្រឡងជាប់ ពួកគេមិនចាំបាច់ប្រឡងម្តងទៀតទេ នៅពេលដែលពួកគេរៀនថ្នាក់ទី១១។ សិស្សណាដែលមិនបានពិន្ទុ ស្ទាត់ជំនាញ ឬ កម្រិតខ្ពស់ (Proficient or Advanced) ក្នុងមុខវិជ្ជាសំខាន់ណាមួយ គេនឹងតម្រូវឲ្យសិស្សនោះប្រឡងម្តងទៀតនៅ ខែឧសភា ឆ្នាំ២០១៣។ សិស្សានុសិស្សទាំងអស់ដែលកំពុងរៀន អង់គ្លេសកម្រិត II ពិជគណិតកម្រិត១ និង ជីវវិទ្យា នឹងប្រឡង Keystone នៅខែឧសភា។

លោកអ្នកនឹងកូនគួរដឹងថា ការប្រឡងនេះគ្មានកំណត់ពេលទេ ដូច្នេះ សិស្សម្នាក់ៗនឹងមានពេលតាមសេចក្តីត្រូវការនៅថ្ងៃប្រឡង។ ការប្រឡងនឹងមាន ចម្លើយសម្រាប់ជ្រើសរើស (៦០-៧៥% នៃការប្រឡង) និង ចម្លើយតាមការពន្យល់ច្បាស់លាស់ (២៥-៤៥% នៃការប្រឡង)។ សិស្សានុសិស្សភាគច្រើននឹងប្រឡងតាមការប្រើ ក្រដាស និងខ្មៅដៃ។ ទោះជាដូច្នេះក៏ដោយ សិស្សានុសិស្សមួយចំនួនតូចអាចប្រឡងតាមអ៊ិនធ័រណិត។

សូមអរគុណជាអតិបរិមាចំពោះការគាំទ្រជាបន្តរបស់លោកអ្នក ដល់គោលបំណងរបស់យើង ក្នុងការជួយសិស្សគ្រប់រូបឲ្យទទួលបានជោគជ័យ នៃសមត្ថភាពដ៏ខ្ពស់បំផុតរបស់ពួកគេ។

ដោយសេចក្តីស្មោះស្ម័គ្រ

Penny Nixon

Penny Nixon

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវ៉ិបសៃ៖ www.philasd.org/language/khmer